ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កំណត់ហេតុ

ស្តីពីការព្យួរកិច្ចសន្យាការងារនៅក្រុមហ៊ុន យីដា មេនូហ្វេកធឺរី ខូអិលធីឌី

ចាប់ពីថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២០ ដល់ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២០

ថ្ងៃអង្គារ ៧កើត ខែពិសាខ ឆ្នាំជូត ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង១០ព្រឹក មានកិច្ចប្រជុំស្តីពីការព្យួរកិច្ចសន្យាការងារនៅក្រុមហ៊ុន យីដា មេនូហ្វេកធឺរី ខូអិលធីឌី ចាប់ពីថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២០ ដល់ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២០ មានទីតាំងស្ថិតនៅផ្លូវលេខ៣៦៩ ភូមិឫស្សីស្រុក ឃុំឈើទាល ស្រុកកៀនស្វាយ ខេត្តកណ្តាល មានកម្មករនិយោជិតត្រូវបានព្យួរកិច្ចសន្យាការងារសរុបចំនួន ៣៨៥៩ នាក់។ ក្រោមអធិបតីភាពលោក តាយ រតនា ជាប្រធានផ្នែកធនធានមនុស្ស ប្រចាំរោងចក្រ យីដា មេនូហ្វេកធឺរី ខូអិលធីឌី។

សមាសភាពចូលរួមមាន៖

១.តំណាងភាគីនិយោជក

១. លោក តាយ រតនា ប្រធានផ្នែកធនធានមនុស្ស

២. លោក Stone Shi តំណាងនាយកក្រុមហ៊ុន

៣. កញ្ញា Eunice Wang ជំនួយការនាយកក្រុមហ៊ុន

៤. លោក លឹម តារា ជំនួយការនាយកក្រុមហ៊ុន

៥. លោក ម៉ុក ភួងមុន្នីរ័ត្ន អនុប្រធានផ្នែកធនធានមនុស្ស

៦. លោកស្រី ឿង គឹមម៉ី បុគ្គលិកសម្របសម្រួលផ្នែកធនធានមនុស្ស

៧. លោកស្រី ឈូ ស្រីពៅ បុគ្គលិកសម្របសម្រួលផ្នែកធនធានមនុស្ស

២.តំណាងកម្មករនិយោជិតសហជីព

១. លោកស្រី ដោក សាវ៉ន់ តំណាងកម្មករ

២. លោក ពេជ្រ សុវត្ថា តំណាងកម្មករ

៣. លោក ហ៊ិន សំរេច តំណាងកម្មករ

៤. លោក សំ ពិសិត្ស តំណាងកម្មករ

| | | | |
|---|---|---|---|
| ៥. លោក ចន ភ័រី | តំណាងកម្មករ | ១៩. លោក លាប ជា | តំណាងកម្មករ |
| ៦. លោកស្រី សុក សារឿន | តំណាងកម្មករ | ២០. លោកស្រី គ្រី ពិសី | តំណាងកម្មករ |
| ៧. លោក សួត ធី | តំណាងកម្មករ | ២១. លោក កុញ សីហា | តំណាងកម្មករ |
| ៨. លោក ព្រុំ សារ៉ាត់ | តំណាងកម្មករ | ២២. លោកស្រី អ៊ុំ ភារី | តំណាងកម្មករ |
| ៩. លោក ជួរ សំណាង | តំណាងកម្មករ | ២៣. លោក សាន់ ចាន់នី | តំណាងកម្មករ |
| ១០. លោក វង្ស វុត្ថា | តំណាងកម្មករ | ២៤. លោកស្រី អ៊ុច សុខណា | តំណាងកម្មករ |
| ១១. លោក ទូច រដ្ឋា | តំណាងកម្មករ | ២៥. លោក ម៉ី ពិសិដ្ឋ | តំណាងកម្មករ |
| ១២. លោក ថាន់ សារ៉ាក់ | តំណាងកម្មករ | ២៦. លោក វ៉េន ស៊ុនរី | តំណាងកម្មករ |
| ១៣. លោក គង់ មិនា | តំណាងកម្មករ | ២៧. លោកស្រី វ៉ាន់ ថាណា | តំណាងកម្មករ |
| ១៤. លោកស្រី ហេង សម្ផស្ស | តំណាងកម្មករ | ២៨. លោកស្រី ម៉ៅ គីមហ៊ាន់ | តំណាងកម្មករ |
| ១៥. លោក ខេត្ត ច័ន្ទមិនា | តំណាងកម្មករ | ២៩. លោកស្រី អាង ស្រីតុល | តំណាងកម្មករ |
| ១៦. លោក ប៊ិច ពៅ | តំណាងកម្មករ | ៣០. លោកស្រី ផាន់ សុភី | តំណាងកម្មករ |
| ១៧. លោកស្រី ជា ភាភ៉ា | តំណាងកម្មករ | ៣១. លោកស្រី ឆាន ចាន្ទី | តំណាងកម្មករ |
| ១៨. លោកស្រី អេង ចិន្តា | តំណាងកម្មករ | ៣២. លោកស្រី យ៉ាន ចរិយា | តំណាងកម្មករ |

(មានភ្ជាប់ជាមួយបញ្ជីវត្តមាន)

ជាកិច្ចចាប់ផ្តើមលោក តាយ រតនា ប្រធានផ្នែកធនធានមនុស្ស បានបើកកិច្ចប្រជុំ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់គ្រប់ភាគីទាំងអស់ដែលបានចូលរួមនៅក្នុងថ្ងៃនេះ និងបានបង្ហាញពីមូលហេតុលើករណីព្យួរកិច្ចសន្យាការងាររបស់បងប្អូនកម្មករកម្មការិនី ចាប់ពីថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២០ ដល់ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២០ ដោយក្រុមហ៊ុនពុំមានការងារគ្រប់គ្រាន់ឲកម្មករធ្វើនៅក្នុងខែឧសភា និងខែមិថុនា ឆ្នាំ២០២០។

៣. ខ្លឹមសារពិភាក្សា

១. ខ្វះវត្ថុធាតុដើមសម្រាប់ផលិតសម្លៀកបំពាក់

២. ការបញ្ជាទិញដែលមាស្រាប់ត្រូវបានបង្អក និងលុបចោលមួយចំនួន

៣. សម្លៀកបំពាក់ដែលបានផលិតរួច និងត្រៀមដឹកចេញត្រូវបានបញ្ឈប់

៤. កម្មការិនីដែលមានផ្ទៃពោះ៧ខែអាចដាក់ច្បាប់សំរាកលំហែមាតុភាព

៥. ការផ្តល់ប្រាក់ឧបត្ថម្ភក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារគឺ ចំនួន៧០ដុល្លាអាមេរិក (៣០ដុល្លាជាបន្ទុករបស់ក្រុមហ៊ុន និង៤០ដុល្លាជាបន្ទុករបស់រដ្ឋ) យោងតាមសេចក្តីណែនាំរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លេខ០៤៥។

៦. របៀបបើកប្រាក់ឧបត្ថម្ភរបស់ក្រុមហ៊ុនក្នុងរយៈពេលព្យួរកិច្ចសន្យាការងារ។

៧. កាតព្វកិច្ចរបស់កម្មករនិយោជិត ដើម្បីទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលក្នុងរយៈពេលព្យួរកិច្ចសន្យាការងារ។

៤ លទ្ធផលពិភាក្សា

១. ក្នុងរយៈពេលព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ២ខែ គិតចាប់ពីថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២០ ដល់ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២០ ក្រុមហ៊ុនបានព្រមព្រៀងផ្តល់ប្រាក់ឈ្នួលជូនកម្មករនិយោជិតចំនួន៣០ដុល្លាអាមេរិកក្នុងមួយខែម្តង ។

២. ការបើកប្រាក់ឈ្នួលជូនកម្មករនិយោជិតក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងាររយៈពេល២ខែ គឺត្រូវផ្តល់ជូនក្នុងរយៈពេល ៧ថ្ងៃ បន្ទាប់ពីថ្ងៃព្យួរកិច្ចសន្យាការងារ ដោយផ្ទេរចូលក្នុងគណនីធនាគារ អេស៊ីលីដារបស់កម្មករនិយោជិតនីមួយៗ។

៣. ដើម្បីទទួលបានប្រាក់ឧបត្ថម្ភចំនួន ៤០ដុល្លាអាមេរិកក្នុង១ខែពីរាជរដ្ឋាភិបាល ត្រូវផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងលេខទូរស័ព្ទដែលអាចទាក់ទងបាន ដោយរង់ចាំទទួលសារតាមទូរស័ព្ទពីធនាគារឯកទេសវីង ចំនួនទឹកប្រាក់ដែលត្រូវទទួលបានក្រោយរយៈពេល១០ថ្ងៃ ដែលរោងចក្របានទទួលលិខិតអនុញ្ញាតព្យួរកិច្ចសន្យាការងារ។ យកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ច្បាប់ដើម) និងទូរស័ព្ទដែលទទួលបានសារនោះទៅភ្នាក់ងារវីងណាមួយដែលនៅជិតផ្ទះ ដើម្បីបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល។ ករណីខកខាន មិនបានទៅបើកប្រាក់ឧបត្ថម្ភក្នុងរយៈពេល១០ថ្ងៃក្រោយពីធនាគារឯកទេសវីងបានផ្ញើរសារជូនបងប្អូននោះ ធនាគារឯកទេសវីង នឹងបង្វិលប្រាក់ដែលបានឧបត្ថម្ភនោះជូនរាជរដ្ឋាភិបាលវិញ។

៤. អំឡុងពេលព្យួរកិច្ចសន្យាការងារប្រសិនបើក្រុមហ៊ុនមានការងារធ្វើវិញ ក្រុមហ៊ុននឹងផ្សព្វផ្សាយព័ត៌មានតាមរយៈទំព័របណ្តាញសង្គមរបស់ក្រុមហ៊ុន ឬទាក់ទងផ្តល់ព័ត៌មានជូនបងប្អូនកម្មករនិយោជិតយ៉ាងតិច២ថ្ងៃមុន។ ក្នុងករណីកម្មករនិយោជិតណាមិនបានមកបំពេញការងារតាមការជូនដំណឹងរបស់ក្រុមហ៊ុនដោយគ្មានមូលហេតុត្រឹមត្រូវទេនោះ ក្រុមហ៊ុននឹងអនុវត្តតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន។

កិច្ចប្រជុំនេះត្រូវបានចប់សព្វគ្រប់នៅវេលាម៉ោង១០៖៥៥នាទីព្រឹក ដោយភាពស្និតស្នាល និងរីករាយក្រៃលែង។

| ភាគីតំណាងក្រុមហ៊ុន | ភាគីតំណាងកម្មករ | អ្នកកត់ត្រា |
| --- | --- | --- |
| គាយ រតនា | | លឹម តារា |